# មេរៀនទី ៤៩: ម៉ូសេជួបព្រះនៅឯគុម្ពបន្លាដែលកំពុងឆេះ

## និក្ខមនំ ២:១១- ៣:២០

**គោលបំណង៖** ព្រះមានអំណាចអស្ចារ្យ។

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ១៤៧:៥** *"ព្រះអម្ចាស់នៃយើងខ្ញុំទ្រង់ធំប្រសើរ ហើយមានឫទ្ធានុភាពក្រៃលែង ឯប្រាជ្ញាញាណរបស់ទ្រង់ក៏យល់គ្រប់ទាំងអស់។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

មនុស្សជាច្រើនប្រឈមមុខនឹងអារម្មណ៍ដែលថាខ្លួនជាមនុស្សគ្មានតម្លៃ។ អរព្រះគុណព្រះយេស៊ូវដែលបានប្រើអស់អ្នកដែលស្ម័គ្រចិត្តធ្វើតាម និងបំរើទ្រង់។ ម៉ូសេក៏មានការសង្ស័យចំពោះខ្លួនឯងដូចគ្នា ប៉ុន្តែគាត់បានទទួលស្គាល់ថា ព្រះបានជ្រើសរើសគាត់សម្រាប់ធ្វើកិច្ចការដ៏ពិសេសមួយ។ តើអ្នកធ្លាប់បរាជ័យ ឬមានបទ-ពិសោធន៍ណាដែលអ្នកភ័យខ្លាចថាអាចជាឧបសគ្គសម្រាប់អ្នកក្នុងការបម្រើព្រះឱ្យបានពេញលេញដែរឬទេ? សូមសារភាពពីការខ្វល់ខ្វាយរបស់អ្នកទៅកាន់ព្រះ ហើយអនុញ្ញាតឱ្យទ្រង់លើកទឹកចិត្តអ្នកជាមួយនឹងសេចក្តី-ពិតនេះ៖ ព្រះនឹងប្រើអស់អ្នកដែលស្ម័គ្រចិត្តបម្រើទ្រង់។ កូនសូមអរគុណដែលបានបម្រើរាស្ត្ររបស់ព្រះអង្គ!

**ចំរៀង៖** ១. ព្រះយើងជាព្រះអស្ចារ្យ ២.ពេលខ្យល់ព្យុះបក់ខ្លាំង ៣. ខ្ញុំទុកចិត្តដល់ព្រះយេស៊ូវ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «ព្រះមានអំណាច»



**សម្ភារៈដែលត្រូវការ៖** ក្រដាស និងខ្មៅដៃឬប៊ិកមួយចំនួន

១. ចែកកុមារជាក្រុម ដែលក្នុង១ក្រុមៗ មានសមាជិកពី ៣-៤ នាក់។

២. ឲ្យក្រដាសនិងប៊ិកទៅក្រុមនីមួយៗ ហើយឲ្យពួកគេ សរសេរនូវអ្វីដែលបង្ហាញថាព្រះជាម្ចាស់មានអំណាច។

៣. ក្រុមដែលសរសេរបានច្រើនជាងគេនឹងឈ្នះល្បែងនេះ! (ចម្លើយអាចជា៖ *មហាសមុទ្រ ផ្កាយ រន្ទះ ខ្យល់ព្យុះ ភ្នំ ថ្ងៃលិច ព្រៃឈើ ការព្យាបាល ការអភ័យទោស និងអ្វីៗជាច្រើនទៀត។*)

### ៤. ការណែនាំមេរៀន

ម៉ូសេបានធំធាត់នៅក្នុងរាជវាំងបន្ទាប់ពីគាត់ត្រូវបានជួយសង្គ្រោះដោយបុត្រីផារ៉ោនដែលជាម្ចាស់ក្សត្រីអេស៊ីព្ទ ។ ថ្ងៃមួយម៉ូសេបានឃើញទាហានអេស៊ីព្ទម្នាក់កំពុងវាយបុរសជនជាតិអ៊ីស្រាអែល ។ ទោះបីជាម៉ូសេធំឡើងនៅក្នុងរាជវាំងក៏ដោយ ក៏គាត់ដឹងថាគាត់ជាជនជាតិអ៊ីស្រាអែលដែរ។ គាត់ខឹងខ្លាំងណាស់ហើយក៏បានសម្លាប់ទាហានអេស៊ីព្ទនោះ។ ក្រោយពីគាត់សម្លាប់គេរួច ម៉ូសេបានរត់គេចខ្លួនព្រោះស្តេចផារ៉ោនបានដឹងអំពីរឿងនេះ ហើយទ្រង់ចង់សម្លាប់ម៉ូសេដើម្បីសងនូវអ្វីដែលគាត់បានធ្វើ ។ ម៉ូសេបានទៅកន្លែងដ៏ឆ្ងាយហើយស្នាក់នៅទីនោះយ៉ាងយូរ។

ក្នុងពេលនោះ រាស្ដ្ររបស់ព្រះក៏នៅតែជាប់ជាទាសករនៅអេស៊ីព្ទនៅឡើយ ពួកគេបានស្រែកយំទូលអង្វរព្រះឲ្យជួយសង្គ្រោះពួកគេ។ តើអ្នកណាអាចជួយសង្គ្រោះជនជាតិអ៊ីស្រាអែលពីស្ដេចអេស៊ីព្ទបាន?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅស្រុកឆ្ងាយមួយដែលមានឈ្មោះថាម៉ាឌាន កាលម៉ូសេកំពុងឃ្វាលចៀមរបស់គាត់ ក៏មានរឿងដ៏អស្ចារ្យមួយបានកើតឡើង។ ព្រះចង់និយាយជាមួយម៉ូសេ ប៉ុន្តែទ្រង់ត្រូវការធ្វើឲ្យម៉ូសេចាប់អារម្មណ៍ជាមុនសិន។ ដូច្នេះទ្រង់បានធ្វើឲ្យគុម្ពបន្លាឆេះដោយអំណាចដ៏អស្ចារ្យរបស់ទ្រង់។ គុម្ពបន្លាបានឆេះមែនប៉ុន្តែមិនឆេះសុសនោះទេ! ព្រះបានធ្វើឱ្យម៉ូសេមានការចាប់អារម្មណ៍លើទ្រង់! ព្រះជាម្ចាស់មានបន្ទូលមកកាន់លោកម៉ូសេពីក្នុងគុម្ពបន្លាថា ឲ្យគាត់ត្រលប់ទៅប្រទេសអេស៊ីព្ទវិញ ហើយប្រាប់ទៅផារ៉ោនឲ្យដោះលែងរាស្ត្ររបស់ព្រះទៅ។

សំរាប់ម៉ូសេ នេះមិនមែនជាការសម្រេចចិត្តដ៏ងាយស្រួលទេ ព្រោះផារ៉ោនចង់សម្លាប់គាត់។ ហើយម៉ូសេក៏មិនប្រាកដថាប្រជាជនអ៊ីស្រាអែលនឹងស្ដាប់តាមគាត់ផងដែរ។ ប៉ុន្តែម៉ូសេនៅតែស្ដាប់បង្គាប់ព្រះ។ ព្រះធ្វើឱ្យម៉ូសេចាប់អារម្មណ៍លើទ្រង់ដោយអំណាចដ៏អស្ចារ្យរបស់ទ្រង់តាមរយៈគុម្ពបន្លាដែលកំពុងឆេះ។ បន្ទាប់មកអំណាចនៃសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់បានយកឈ្នះចិត្តរបស់ម៉ូសេ។ ហើយប្រាជ្ញាដ៏ខ្លាំងពូកែរបស់ទ្រង់បានធ្វើឲ្យម៉ូសេចង់ស្ដាប់តាមបង្គាប់ទ្រង់។ ម៉ូសេបានឆ្លើយតបទៅកាន់ព្រះជាម្ចាស់ដោយធ្វើនូវអ្វីគ្រប់យ៉ាងដែលព្រះបានបង្គាប់។ សូមធ្វើឲ្យដូចជាម៉ូសេ ដោយស្ដាប់បង្គាប់ព្រះ ព្រោះព្រះរបស់យើងទ្រង់អស្ចារ្យ!

## ៦. សំនួរពិភាក្សា

១.តើម៉ូសេបានឃើញអ្វីនៅខាងក្រៅរាជវាំង? *ទាហានអេស៊ីព្ទម្នាក់វាយបុរសជនជាតិអ៊ីស្រាអែលម្នាក់*

២.តើផារ៉ោនចង់ធ្វើអ្វីនៅពេលគាត់ដឹងថាម៉ូសេសម្លាប់ទាហានអេស៊ីព្ទ? *ផារ៉ោនចង់សម្លាប់ម៉ូសេ*

៣.តើព្រះបានធ្វើអ្វីដើម្បីធ្វើឲ្យម៉ូសេចាប់អារម្មណ៍លើទ្រង់? *ទ្រង់ដុតគុម្ពបន្លាប៉ុន្តែគុម្ពបន្លាមិនឆេះសុសនោះទេ*

៤.តើព្រះចង់ឲ្យម៉ូសេធ្វើអ្វីសំរាប់ជនជាតិអ៊ីស្រាអែល?

*ត្រឡប់ទៅអេស៊ីព្ទវិញហើយជួយសង្គ្រោះជនជាតិអ៊ីស្រាអែលពីភាពជាទាសករ*

៥.តើប្អូនគិតថា ព្រះកំពុងប្រើប្អូនធ្វើអ្វីខ្លះដើម្បីជួយដល់ក្រុមគ្រួសារ សហគមន៍និង អ្នកដទៃ?

*ទុកឲ្យកុមារជាអ្នកឆ្លើយ*

## ៧. ល្បែងកំសាន្ត «ព្រះយេស៊ូវបញ្ជា»

**របៀបលេង:** យើងលេងល្បែងព្រះយេស៊ូវបញ្ជាដោយគ្រូដើរតួធ្វើជាព្រះយេស៊ូវ នៅពេលដែលកុមារឮពាក្យ "ព្រះយេស៊ូវបញ្ជា" កុមារត្រូវធ្វើតាមអ្វីដែលគ្រូបានប្រាប់ដូចជា ប៉ះក្បាល លោតឡើង សើច...។ បើសិនជាមិនឮពាក្យថា "ព្រះយេស៊ូវបញ្ជា" ទេកុមារមិនត្រូវធ្វើតាមឡើយ។ ពេលខ្លះគ្រូអាចព្យាយាមធ្វើបន្លំឲ្យកុមារ ធ្វើខុសតាមដែរ ដោយគ្រូធ្វើកាយវិការតែអត់ស្រែកថា "ព្រះយេស៊ូវបញ្ជា" ទេ។

## ៨. ខគម្ពីរចងចាំ ទំនុកដំកើង ១៤៧:៥

## ៩. ហត្ថកម្ម



យកក្រដាសមួយបត់ជាពីរហើយកាត់ជាការ៉េនៅចំកណ្តាល រួចហើយយកក្រដាសនោះមកស៊កលើក្បាលនិងខ្លួនទាំងអស់គ្នា ហើយសួរកុមារថា តើគេគិតថាក្រដាសរាងការ៉េនេះអាចស៊ក ក្បាលនិងខ្លួនពួកគេចូលដែរឬទេ? កុមារនឹងនិយាយថាគេស៊កមិនចូលនោះទេ ពីព្រោះការ៉េតូចពេក។



បន្ទាប់មកកាត់ក្រដាសដែលបត់ដូចបង្ហាញនៅរូបខាងស្តាំ។ បន្ទាប់ពីបានកាត់រួចហើយ សូមលាតក្រដាសនោះឲ្យអស់។ ឥឡូវនេះសូមសួរកុមារថា តើពួកគេគិតថាពួកគេអាចស៊កក្បាល និងខ្លួន នឹងក្រដាសនេះបានដែរឬទេ? ត្រូវហើយខ្ញុំអាចស៊កវាបានព្រោះវាធំ។

ទោះបីជានៅក្នុងជីវិតរឿងខ្លះហាក់ដូចជាមិនអាចទៅរួចក៏ដោយ តែជាមួយនឹងអំណាចរបស់ព្រះអ្វីក៏អាចទៅរួចដែរ!

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*